

# កម្មវិធីអាហារូបករណ៍ របស់កម្មវិធីអភិវឌ្ឍន៍ជំនាញ ការងារឌីជីថល




*វាគ្មានដែនកំណត់សម្រាប់យើងដែលជាស្ត្រីនោះទេ។*
*យើងពិតអាចធ្វើកិច្ចការឱ្យសម្រេចបាន។*

USAID FROM THE AMERICAN PEOPLE

BLUM CENTER FOR DEVELOPING ECONOMIES University of California, Berkeley

## ទិដ្ឋភាពរួម

អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប) បានបង្រួមគម្រោងតូចៗ និងមធ្យមមួយចំនួនផ្តោតលើការអប់រំបរិយាបន្នឱ្យស្ថិតនៅក្រោមឆ័ត្រតែមួយហៅថា កម្មវិធីអប់រំបរិយាបន្ន។ កម្មវិធីគឺមានគោលដៅចម្បងគឺបង្កើនការទទួលបានការអប់រំ ជាពិសេសក្មេងស្រីជនជាតិខ្មែរឥស្លាម និងកុមារ/យុវជនដែលងាយរងគ្រោះ។ កម្មវិធី IEP ជួយដល់កុមារ និងយុវជនជាច្រើនចាប់ពីកម្រិតអនុវិទ្យាល័យដល់វិទ្យាល័យ វិជ្ជាជីវៈ និងកម្រិតបណ្តុះបណ្តាលជំនាញ។ រួមបញ្ចូលទាំងកម្មវិធីអភិវឌ្ឍន៍ជំនាញឌីជីថល (DWD)។ កម្មវិធី IEP មានគម្រោងចំនួន៤ រួមមាន៖ គម្រោងអាហារូបករណ៍សម្រាប់និស្សិតកម្រិតឧត្តមសិក្សា (CTSP) គម្រោងស្ទែមសម្រាប់ស្ត្រី (STEM4Women) និងគម្រោងអប់រំកុមារី (GEI) ។

## អំពីកម្មវិធីអាហារូបករណ៍

*កម្មវិធីអាហារូបករណ៍របស់ USAID គឺជាផ្នែកមួយនៃគម្រោងអភិវឌ្ឍន៍ជំនាញការងារឌីជីថល ដែលគាំទ្រដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) តាមរយៈសាកលវិទ្យាល័យ California at Berkeley (UCB)។*

*អង្គការមូលនិធិអាស៊ីធ្វើការជិតស្និទ្ធជាមួយអង្គការ ខេប នឹងគ្រប់គ្រង តាមដានកម្មវិធីអាហារូបករណ៍។*

## គោលដៅ

ក្មេងស្រី១២នាក់មកពីខេត្តចំនួន៨ ដែលបានបញ្ចប់ការសិក្សានៅថ្នាក់វិទ្យាល័យ ទទួលបានអាហារូបករណ៍រយៈពេល៤ឆ្នាំ ដើម្បីសិក្សានៅសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ ឯកទេស វិទ្យាសាស្ត្រកុំព្យូទ័រ និងវិស្វកម្មព័ត៌មានវិទ្យា។

***សិស្សត្រូវបានជ្រើសរើស***




## គោលដៅគម្រោង

*គម្រោងមានគោលបំណងផ្សារភ្ជាប់ស្ថាប័នឯកជនដៃគូ ដើម្បីជួយអភិវឌ្ឍ និងបង្កើតអាហារូបករណ៍ដែលបង្កើនការទទួលស្គាល់គុណភាព និងកម្មវិធីថ្នាក់បរិញ្ញាបត្រសម្រាប់សិស្សសិក្សាបញ្ចូលគ្នា និងសិស្សដែលមានសមត្ថភាព។*

*កម្មវិធីអាហារូបករណ៍គាំទ្រដល់និស្សិតស្រីដើម្បីទទួលបានឱកាសបន្តការសិក្សានៅកម្រិតឧត្តមសិក្សាលើជំនាញពាក់ព័ន្ធនឹងឌីជីថល។*







## ជំនាញសិក្សា

- *វិទ្យាសាស្ត្រកុំព្យូទ័រ*
- *វិស្វកម្មព័ត៌មានវិទ្យា*

# ដំណាក់កាលសំខាន់ៗ របស់គម្រោង DWD

**ដំណាក់កាលទី១៖** ប្រកាស និងការជ្រើសរើស

**ដំណាក់កាលទី២៖** បណ្តុះបណ្តាលជំនាញ

**ដំណាក់កាលទី៣៖** តម្រង់ទិសការងារ

**ដំណាក់កាលទី៤៖** ចូលរួមក្នុងបណ្តាញនិស្សិតអាហារូបករណ៍




**ទំនាក់ទំនង៖**

**លោកស្រី ហ៊ឹម ម៉ារី**

*អ្នកសម្របសម្រួលកម្មវិធី IEP*

លេខទូរសព្ទ៖ 012/15 521 866

អ៊ីម៉ែល៖ mary@kapekh.org

www.kapekh.org

www.facebook.com/kapeaction


# សកម្មភាព

- បណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យា
- ក្លឹបសិក្សា
- បណ្តុះជំនាញទន់
- ប្រជុំប្រចាំខែ
- តម្រង់ទិសការងារ
- ចូលជាសមាជិកសិស្សអាហារូបករណ៍



# ការគាំទ្រពីកម្មវិធីអាហារូបករណ៍

- ថ្លៃសិក្សា
- ប្រាក់ឧបត្ថម្ភថ្លៃអាហារ
- កន្លែងស្នាក់នៅ
- សម្ភារៈសិក្សា
- ថ្លៃទឹកភ្លើង
- ប្រជុំអាណាព្យាបាល
- កុំព្យូទ័រយួរដៃ
- បណ្តុះបណ្តាលដើម្បីអភិវឌ្ឍអាជីព
- ការធានារ៉ាប់រងសុខភាព

